កំណាព្យ

# ផ្ទះខ្មែរ

(បទភាគគតិ)



និពន្ធដោយលោក វ៉ែន សុន

វិចិត្ររូបភាពដោយ លោក គាំ សាវ៉ែន

បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត

នេះនឹងចារចែង ពាក្យកាព្យថ្លាថ្លែង អំពីផ្ទះខ្មែរ

មានច្រើនសណ្ឋាន បុរាណបានថែ សម័យផងដែរ

ហូរហែប្លែកគ្នា ។



ខ្ទមស្លឹកទាបខ្ពស់
នៅចំការស្រែ

គ្រួសាររួមរស់
ពុកម៉ែមីងមា
ភោគផលដំណាំ ។

ការក្តៅរងា
ស្នាក់នៅការពារ



រោងខ្ពស់វែងខ្លី
រោងខ្លះផ្ទាល់ដី
រោងថ្មីចូលឆ្នាំ
រោងការរោងបុណ្យ
ល្ខោនកុនឆៃយ៉ាំ
រោងរាំរបាំ
ហៅរោងសិល្បៈ ។

